វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

ឆ្នាំ២០១៤ លេខ ០១

## កម្ពុជាក្នុងប្រាំឆ្នាំទៅមុខ
## របៀបវារៈសម្រាប់កំណើនរឹងមាំ និងភាពប្រកួតប្រជែង

"នេះជាពេលវេលាដ៏សំខាន់បំផុត ដែលយើងត្រូវធ្វើការងាររួមគ្នា ដើម្បីសន្តិភាព ស្ថិរភាព ការអភិវឌ្ឍ និងវិបុលភាពទៅថ្ងៃអនាគតនៅកម្ពុជា។"

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

### មូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការផ្លាស់ប្តូរ

កម្ពុជា កំពុងឈានចូលក្នុងដំណាក់កាលថ្មីមួយនៃការរីកលូតលាស់ ជាមួយនឹងការរំពឹងថា នឹងមានការផ្លាស់ប្តូរក្នុង រចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ សេចក្តីប្រាថ្នារបស់ប្រជាជន និងលក្ខខណ្ឌទីផ្សារក្នុងតំបន់។គេព្យាករណ៍ថានឹងមានការផ្លាស់ប្តូរសំខាន់ៗពីរ ក្នុង៥ឆ្នាំខាងមុខ។ ទី១ ការធ្វើសមាហរណកម្មចូលទៅក្នុង សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) នឹងបើកចំហទីផ្សារថ្មីៗសម្រាប់ផលិតផលកម្ពុជា ប៉ុន្តែការប្រកួតប្រជែងពីសំណាក់ផលិតករក្នុងតំបន់ក៏កើនឡើងដែរ។ ទី២ ឧត្តមភាពប្រៀបធៀបរបស់កម្ពុជានឹងងាកចេញពី ផលិតកម្មអតិពលកម្មមានតម្លៃទាប នៅពេលដែលកម្ពុជាឡើងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

អ្នកធ្វើគោលនយោបាយ កំពុងមានស្ថានភាពល្អដើម្បីធ្វើការឆ្លងកាត់អន្តរកាល បន្ទាប់ពីកម្ពុជាសម្រេចបានកំណើន ផសស យ៉ាងខ្លាំងក្នុងពីរទសវត្សរ៍កន្លងទៅនេះ។ បើគិតពី កំណើនសេដ្ឋកិច្ចខ្ពស់ និងបិតថេរវិញ សេដ្ឋកិច្ចកម្ពុជាគឺជា រឿងជោគជ័យមួយនៅចុងសតវត្សរ៍ទី២០ នេះ ដោយមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧,៨% ពីឆ្នាំ១៩៩៤ ដល់ ២០១១។ នៅឆ្នាំ២០១៣ កម្ពុជា សម្រេចបានកំណើនសេដ្ឋកិច្ច ៧,៦% ហើយគេគន់គូរថា នឹងមានអត្រាកំណើនប្រចាំឆ្នាំប្រហែល ៧% ក្នុង ៥ឆ្នាំទៅមុខទៀត។

តួលេខសម្រាប់ឆ្នាំ២០១៣ បង្ហាញថា កំណើនជំរុញដោយការនាំចេញរបស់កម្ពុជាមាននិន្នាការតទៅមុខល្អណាស់។ ការនាំចេញសរុបកើន ១៦,២% នៅឆ្នាំ២០១៣ ដល់ ៦,៩៩ពាន់លានដុល្លារ ដែលជំរុញឡើងដោយ លទ្ធផលខ្លាំងក្លាក្នុងវិស័យស្នូលជាច្រើននៃសេដ្ឋកិច្ច។ ការនាំចេញសម្លៀកបំពាក់កើន ១៧,៣% ស្បែកជើងកើន ២១,៣% និងទេសចរណ៍កើន ១៧,៣%។ ការនាំចេញអង្ករកើន ៨៤%ដល់៣៧៩.០០០តោនដោយនិន្នាការកំណើនផលិតកម្មយ៉ាងខ្លាំងចាប់ពីឆ្នាំ ២០០៩ មកនោះ កំពុងបន្តទៅមុខទៀត (រូបភាព ១)។ វិនិយោគផ្ទាល់ពីបរទេស (FDI) មានតួលេខប៉ាន់ស្មានឡើងដល់ ១,២២ពាន់លានដុល្លារ ក្នុងឆ្នាំ២០១៣ ដែលលើសពីកម្រិតនៅមុនពេលមានវិបត្តិហិរញ្ញវត្ថុសកល ប៉ុន្តែមិនទាន់ឡើងដល់កម្រិតខ្ពស់បំផុត ១,៤១ពាន់លានដុល្លារ ក្នុងឆ្នាំ២០១២ នោះទេ។

រូបភាព ១៖ ការនាំចេញអង្ករ គិតជា តោន




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏មធ្យ័ត បានរក្សាអតិផរណាឲ្យមានកម្រិតទាបក្នុងពីរទសវត្សរ៍កន្លងទៅ (ជាមធ្យម ៥,៥% ពីឆ្នាំ ១៩៩៤ ដល់ ២០១១)។ អតិផរណានៅឆ្នាំ២០១៤ រំពឹងថានឹងធ្លាក់ចុះថែមទៀតមកត្រឹម ៣% ទៅ ៤% ទោះបី អតិផរណាក្នុងតំបន់

---

អត្ថបទនេះ សង្ខេបចេញពី វគ្គទី១ នៃការពិភាក្សាតាមក្រុម ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤។អ្នកចូលរួមក្នុងវគ្គនេះរួមមាន ឯកឧត្តម បណ្ឌិតវង្សីវិស្សុតរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បណ្ឌិត Faisal Ahmed តំណាង នៃមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសកម្ពុជា, លោកស្រី ឡាយ សុគន្ធា នាយកក្រុមហ៊ុន CSCS Cornerstone Co., Ltd និង បណ្ឌិត Jayant Menon សេដ្ឋវិទូជាន់ខ្ពស់ (ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់) នៅការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ នៃធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំទីក្រុងម៉ានីល។ អ្នកសម្របសម្រួលវគ្គនេះគឺ លោក Grant Knuckey អគ្គនាយកនៃធនាគារ ANZ Royal។

មានកម្រិតខ្ពស់ ហើយ ប្រេងកាត និងស្បៀងអាហារបានឡើងថ្លៃយ៉ាងគំហុកក្ដី។

សូចនាករម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត ក៏បង្ហាញពីស្ថិរភាពក្នុងពេលខាងមុខដែរ៖ នៅឆ្នាំ២០១៣ ប្រាក់រៀលមានស្ថិរភាពទល់នឹងប្រាក់ដុល្លារ, ប្រាក់បញ្ញើនៅធនាគារ និងប្រាក់កម្ចីពីធនាគារ បានកើនឡើង, សាច់ប្រាក់ងាយស្រួលមានចំនួនគ្រប់គ្រាន់នៅក្នុងទីផ្សារ, ហើយបំណុលខាងក្រៅធ្លាក់ចុះជិតដល់ ២៣% នៃ ផសស ។ តាមការប៉ាន់ស្មាន ឱនភាពថវិកា មានប្រហែល ៦,៨% នៃ ផសស ហើយនឹងធ្លាក់ចុះមកទាបជាង ៥,៣% នៅឆ្នាំ២០១៤។ នៅក្នុងរយៈពេលមធ្យម រដ្ឋាភិបាលមានគោលដៅបញ្ចុះតួលេខនេះថែមទៀត ឲ្យនៅត្រឹម ៣% ដូចមុនពេលមានវិបត្តិហិរញ្ញវត្ថុសកល។ ការប្រមូលចំណូលសាធារណៈក៏បានប្រសើរឡើងគួរឲ្យពេញចិត្តដែរ ហើយរដ្ឋាភិបាលរំពឹងថា ចំណូលពីការបង់ពន្ធ នឹងកើនឡើង ១៤,៥% ក្នុងឆ្នាំ២០១៤។

លទ្ធផលម៉ាក្រូសេដ្ឋកិច្ចរឹងមាំ បានបណ្ដាលឲ្យអត្រាភាពក្រីក្រថយចុះពី៥៣%នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ២០០៤មកត្រឹម២០% ក្នុងឆ្នាំ២០១៣។ ប្រសិនបើនិន្នាការបច្ចុប្បន្នបន្តទៅមុខទៀត គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ស្ដីពីការកាត់បន្ថយភាពក្រីក្រឲ្យបានពាក់កណ្ដាល ពីឆ្នាំ ២០០០ ដល់ ២០១៥ ពិតជាសម្រេចបាន។

ផ្អែកលើមូលដ្ឋានគ្រឹះដ៏រឹងមាំទាំងនេះ អ្នកធ្វើគោលនយោបាយត្រូវបន្តកសាងសេដ្ឋកិច្ចឲ្យមានលក្ខណៈប្រកួតប្រជែង និងសម្បូរបែបដែលអាចជួយឲ្យដំណាក់កាលបន្ទាប់នៃកំណើនសេដ្ឋកិច្ចកម្ពុជា កាន់តែមានជោគជ័យខ្លាំងឡើង។

## អាទិភាពខ្ពស់នៃការអភិវឌ្ឍសម្រាប់គ្រប់គ្នា

ដើម្បីរក្សាស្ថិរភាព និងកំណើនក្នុងអំឡុងពេលខាងមុខនៃការផ្លាស់ប្ដូរក្នុងសង្គម សេដ្ឋកិច្ច និងនយោបាយនោះ កម្ពុជាត្រូវមានគោលនយោបាយដើម្បីធានាឲ្យ កំណើន ផសស ដ៏ខ្ពស់នេះវាចែកចាយប្រកបដោយសមធម៌ទៅដល់ប្រជាជនគ្រប់ស្រទាប់។ បណ្ដាប្រទេសដែលមានអត្រាភាពក្រីក្រ និងវិសមភាពកម្រិតទាប និងមានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរឹងមាំឈរលើបទបញ្ញត្តិច្បាប់ប្រកបដោយសមធម៌ និងតម្លាភាព តែងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ល្អជាងប្រទេសដទៃទៀត។ រដ្ឋាភិបាលក៏មានកាតព្វកិច្ចជាច្រើនចំពោះប្រជាជនខ្លួនដែរ ដូច្នេះត្រូវប្រឹងប្រែងធ្វើការដើម្បីសម្រេចបានសង្គមមួយកាន់តែមានយុត្តិធម៌ និងសមភាពឡើង។

ការកាត់បន្ថយភាពក្រីក្រទទួលបានជោគជ័យយ៉ាងច្រើន ក្នុងពីរទសវត្សរ៍កន្លងទៅនេះ ប៉ុន្តែប្រជាជនក្រីក្រនៅកម្ពុជា នៅតែងាយរងគ្រោះ សូម្បីមានការប្រែប្រួលតែបន្តិចបន្តួចក្នុងប្រាក់ចំណូលក្ដី។ នៅឆ្នាំ២០០៩ CDRI បានរកឃើញថា ប្រជាជនកម្ពុជាប្រហែល ២០% រកចំណូលបានត្រឹមតែចិញ្ចឹមពោះ ដោយមានចំណាយប្រចាំថ្ងៃតិចជាង ១,២៥ដុល្លារ ហើយប្រជាជនប្រហែល ៥០% ត្រូវរស់នៅ ដោយមានចំណាយប្រចាំថ្ងៃតិចជាង ២ដុល្លារ។ គ្រួសារប្រភេទនេះតែងងាយរងគ្រោះ ដោយសារការប៉ះទង្គិចផ្សេងៗបណ្ដាលមកពី គ្រោះធម្មជាតិ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ឬបណ្ដាលមកពី ការចំណាយទៅលើសេវាថែទាំសុខភាព។

វិសមភាពលើទ្រព្យធន ជាពិសេស វិសមភាពដីធ្លី និងបញ្ហាទាក់ទងនឹងអសន្តិសុខក្នុងការកាន់កាប់ដី ជាមូលហេតុចម្បងមួយនៃភាពក្រីក្រ។ បច្ចុប្បន្ន ៥៥% នៃគ្រួសារនៅជនបទជាអ្នកក្រីក្រដីធ្លី (រូបភាព ២)។ ពួកគេមិនមានដីធ្លី ឬមួយមានដីតិចដាំដុះបានត្រឹមតែចិញ្ចឹមពោះ។ គ្រួសារទាំងនេះ ត្រូវជាប់ផុងក្នុងភាពក្រីក្រ ហើយមិនអាចមានអតិរេកផលិតផល ជួយរួមចំណែកដល់កំណើនសេដ្ឋកិច្ចបានទេ។

រូបភាព ២៖ ស្ថានភាពកម្មសិទ្ធិដីកសិកម្មនៃគ្រួសារនៅជនបទក្នុងឆ្នាំ២០១១




ប្រភព៖ CSES 2011

សម្ដេចនាយករដ្ឋមន្ត្រី បានប្ដេជ្ញាកសាងសមត្ថភាពស្ថាប័នរដ្ឋបាលដីធ្លីដើម្បីការពារតាមច្បាប់នូវសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ម្ចាស់ដីតូចៗទប់ទល់នឹងការដកហូតដីធ្លី និងដើម្បីជំរុញវិនិយោគ ដោយបានគូសបញ្ជាក់ថា នេះជាអាទិភាពគោលនយោបាយនៃរដ្ឋាភិបាលក្នុងអាណត្តិទី៥។ រដ្ឋាភិបាលនឹងបន្តកិច្ចប្រឹងប្រែងបង្កើនបទបញ្ញត្តិសម្រាប់គ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ហើយធ្វើការបែងចែកដីធ្លីឡើងវិញនៅតាមតំបន់សមស្រប។

ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ដែលផ្ដល់នូវសន្តិសុខដល់ការកាន់កាប់ដី គឺជាបុរេលក្ខខណ្ឌមួយសម្រាប់ការធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការជំរុញឧស្សាហូបនីយកម្ម។ បទពិសោធន៍នៅតាមប្រទេសឧស្សាហកម្មថ្មីៗ បង្ហាញថា គ្រួសារដែលមានប័ណ្ណកម្មសិទ្ធិរឹងមាំច្រើនតែចាកចេញពីដីធ្លីរបស់ខ្លួន ហើយចូលទៅតំបន់ទីប្រជុំជនដើម្បីធ្វើការងារដែលជួយជំរុញឧស្សាហកម្មឡើង ហើយនេះជាកត្តាដ៏សំខាន់មួយនៃការផ្លាស់ប្ដូរសេដ្ឋកិច្ច។ កម្មសិទ្ធិដីក៏រួមចំណែកក្នុងដំណើរការរីកលូតលាស់ទីផ្សារផ្លូវការដែរព្រោះវាផ្ដល់នូវមូលដ្ឋានមួយសម្រាប់ការពង្រីកឥណទានផ្លូវការ និងហេដ្ឋារចនាសម្ព័ន្ធសេវាកម្ម។

ការលុបបំបាត់ រាល់ឧបសគ្គដែលរារាំងផលិតភាពរបស់ម្ចាស់ដីតូចៗ ជាកត្តាសំខាន់បំផុតដើម្បីញ៉ាំងឲ្យប្រជាជនជនបទមួយភាគធំបានទទួលអត្ថប្រយោជន៍ពីកំណើន ហើយក្នុងនេះ ការអនុវត្តគោលនយោបាយត្រូវតែមានការសម្របសម្រួលគ្នា។ ឧបសគ្គចម្បងៗរួមមាន បន្ទុកចំណាយខ្ពស់ក្នុងផលិតកម្ម និងពាណិជ្ជកម្ម, ការដាំដុះភាគច្រើនអនុវត្តតាមបែបប្រពៃណី, និង កង្វះហេដ្ឋារចនាសម្ព័ន្ធបណ្ដុះបណ្ដាល។ កង្វះការផ្ដល់សេវាថែទាំសុខភាព និងប្រព័ន្ធសុវត្ថិភាពសង្គម បានធ្វើឲ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរឡើង ព្រោះវាបង្វែរធនធានចេញពីសកម្មភាពមានផលិតភាពខ្ពស់។ គេប៉ាន់ស្មានថា បញ្ហាកង្វះអាហារូបត្ថម្ភអាចជះឥទ្ធិពលអវិជ្ជមានទៅលើ ផសស រហូតដល់ ២,៥% ក្នុងប្រាំឆ្នាំខាងមុខ។

រដ្ឋាភិបាល ក៏ត្រូវព្យាយាមដាក់បញ្ចូលប្រជាជនក្រីក្រដែលគ្មានដីកសិកម្ម ទៅក្នុងដំណើរការរីកលូតលាស់ផងដែរ។ នៅតំបន់ជនបទការដាក់បញ្ចូលនេះសំដៅដល់ ការបង្កើនឱកាសការងារនៅតាមចំការកៅស៊ូ និងចំការដំឡូងឈើ, ការអភិវឌ្ឍតំបន់នេសាទ, និងការផ្ដល់វគ្គបណ្ដុះបណ្ដាលលើការងារក្រៅពីកសិកម្ម។ កំណើនសកម្មភាពនគរូបនីយកម្មយ៉ាងលឿន ដោយសារមាន កំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម កំពុងតែបង្កើតឡើងនូវ វណ្ណៈពលករតំបន់ទីក្រុង ដូច្នេះត្រូវមានគោលនយោបាយ សម្រាប់ជួយដោះស្រាយភាពងាយរងគ្រោះ។រដ្ឋាភិបាលត្រូវបង្កើតគោលនយោបាយបៀវត្សរ៍ថ្នាក់ជាតិប្រកបដោយយុត្តិធម៌ ដែលថ្លឹងថ្លែងបានល្អរវាង តម្រូវការឲ្យបន្ទុកចំណាយផលិតកម្មមានលក្ខណៈប្រកួតប្រជែង ហើយនឹងតម្រូវការឲ្យពលករមានកម្រិតជីវភាពសមរម្យ។ ត្រូវបង្កើតផងដែរនូវប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីការពារគ្រួសារងាយរងគ្រោះអំពីវិបត្តិសេដ្ឋកិច្ចផ្សេងៗ។

រដ្ឋាភិបាលបាននិងកំពុងផ្ដល់អាទិភាពលើ ការបណ្ដុះបណ្ដាល និងអប់រំ ទុកជាឧបករណ៍ដ៏សំខាន់ក្នុងការអភិវឌ្ឍសម្រាប់គ្រប់គ្នា។ ក្នុងនេះ ជំនាញបច្ចេកទេសត្រូវតែពង្រឹងពង្រីកបន្ថែម ដើម្បីឲ្យកម្លាំងពលកម្មនៅទីជនបទដែលខ្វះការងារធ្វើនោះ មានជំនាញដ៏ចាំបាច់ៗសម្រាប់ជួយជំរុញឧស្សាហូបនីយកម្ម និងពិពិធកម្ម។ ដូច្នេះត្រូវមានការពង្រីកគម្រោងការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស (TVET) និងការផ្សព្វផ្សាយផ្ដល់គម្រោងទាំងនេះទៅកាន់តំបន់ដាយៗ។ ការបណ្ដុះបណ្ដាលក៏សំខាន់ណាស់ដែរសម្រាប់ពលករក្នុងវិស័យកសិកម្ម ដើម្បីជ្រើសយករបៀបដាំដុះថ្មីៗ មកបង្កើនផលិតភាពដំណាំផ្សេងៗ។

## ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចជាលក្ខណៈយុទ្ធសាស្ត្រ

ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងប្រាំឆ្នាំខាងមុខ ខណៈដែលសេដ្ឋកិច្ចនយោបាយកាន់តែស្មុគស្មាញ និងចោទបញ្ហាថ្មីៗច្រើនឡើងដល់អ្នកធ្វើគោលនយោបាយ។ សញ្ញាសំខាន់ៗនៃការប្រែប្រួលបរិយាកាសម៉ាក្រូហិរញ្ញវត្ថុ បានបង្ហាញឡើងរួចជាស្រេច។ ជាអាទិ៍ តាមតួលេខរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អនុបាតឥណទាន ធៀបនឹង ផសស បានកើនឡើងយ៉ាងលឿន ពីរវាង ៦% ទៅ ៩% នៅឆ្នាំ ២000-២00៥ ដល់ជិត ៤០% ក្នុងឆ្នាំ ២០១៣។ កំណើនឥណទានយ៉ាងលឿននេះកើតមានឡើងនៅក្នុងទីផ្សារមួយមានមនុស្សកកកុញ គ្មានបទបញ្ញត្តិច្បាប់គ្រប់គ្រាន់ និងមានការប្រើប្រាក់ដុល្លារជាសំខាន់ ដែលអាចបង្កជាហានិភ័យផ្សេងៗ។

យន្តការប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រប់គ្រងត្រួតពិនិត្យលើអ្នកផ្ដល់ឥណទាន ចាំបាច់ត្រូវតែបង្កើតឡើង។ អ្នកធ្វើគោលនយោបាយត្រូវថ្លឹងថ្លែងឲ្យបានល្អរវាង តម្រូវការកាត់បន្ថយហានិភ័យផ្នែកម៉ាក្រូហិរញ្ញវត្ថុ នឹងការផ្ដល់ក្របខ័ណ្ឌអំណោយផលមួយសម្រាប់កំណើនឥណទាន និងការពង្រីកសេវាឥណទានក្នុងទូទាំងប្រទេស ជាពិសេសសម្រាប់ សហគ្រាសធុនតូចនិងមធ្យម (SMEs) និងកសិករដាំស្រូវដែលមានដីតូចៗ។ កិច្ចការនេះទាមទារនូវវិធីសាស្ត្រជារួមមួយដែលផ្ដោតលើ ឥណទានក្នុងបរិបទនៃដំណើរការជំរុញឲ្យទីផ្សារហិរញ្ញវត្ថុមានលក្ខណៈជាផ្លូវការត្រឹមត្រូវឡើង។

បច្ចុប្បន្ន ឧស្សាហកម្មនៅកម្ពុជាភាគច្រើនមិនទាន់អនុវត្តដំណើរការហិរញ្ញវត្ថុតាមបែបផ្លូវការទេ ដូចជាក្នុង ការចុះបញ្ជីអាជីវកម្មសវនកម្មឯករាជ្យ និងការបង់ពន្ធ ជាពិសេសក្នុងចំណោម SMEs ដែលតំណាងឲ្យមួយភាគធំនៃក្រុមហ៊ុននៅកម្ពុជា។ រចនាសម្ព័ន្ធមិនផ្លូវការនៃអាជីវកម្ម ជាប្រភពចម្បងមួយនៃភាពមិនប្រាកដប្រជានៅក្នុងទីផ្សារ ហើយជាឧបសគ្គរាំងដល់ការពង្រីកឥណទានពីសំណាក់អ្នកផ្ដល់កម្ចីក្នុងវិស័យផ្លូវការជាច្រើន និងដល់ការធ្វើវិនិយោគ។

ការធ្វើឲ្យរបៀបរបបហិរញ្ញវត្ថុ មានលក្ខណៈផ្លូវការឡើង ក៏នឹងបន្តលើកស្ទួយសមិទ្ធផលថ្មីៗ ក្នុងការប្រមូលពន្ធ ព្រមទាំងបង្កើនលទ្ធភាពផ្នែកសារពើពន្ធ ដើម្បីផ្ដល់ទុនជួយលើកកម្ពស់ការផ្ដល់សេវាសង្គមដែលកំពុងមានតម្រូវការខ្លាំង និងផ្ដល់ធនធានសម្រាប់ឲ្យសេដ្ឋកិច្ចអាចទប់ទល់បាននឹងការប៉ះទង្គិចផ្សេងៗពីផ្នែកខាងក្រៅ។ យន្តការផ្នែកស្ថាប័នក៏ត្រូវដាក់អនុវត្តដែរ ដើម្បីញាំងឲ្យការប្រើប្រាស់ធនធានទាំងនេះមានប្រសិទ្ធភាពបំផុត មានជាអាទិ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីអាចមើលឃើញពីហានិភ័យសេដ្ឋកិច្ចដែលប្រុងកើតមាន, ការឆ្លើយតបបានសមស្របទៅនឹងស្ថានភាពអាសន្នផ្សេងៗ និងការកៀងគរយ៉ាងមានប្រសិទ្ធភាពនូវធនធានសម្រាប់កំណែទម្រង់សង្គម។

គោលនយោបាយសារពើពន្ធក៏សំខាន់ដែរ ក្នុងការរក្សាតុល្យភាពសេដ្ឋកិច្ច ដើម្បីទាញយកប្រយោជន៍បានកាន់តែច្រើនពីសមាហរណកម្មក្នុងតំបន់ និងជំរុញឧស្សាហកម្មថ្មីៗខណៈដែលឧត្ដមភាពប្រៀបធៀបរបស់កម្ពុជាកំពុងផ្លាស់ប្ដូរចេញពី កម្លាំងពលកម្មមានតម្លៃទាប។ នាបច្ចុប្បន្ន ច្បាប់វិនិយោគមានគោលដៅទាក់ទាញ FDI ដូច្នេះត្រូវតែកែសម្រួលឡើងវិញ ដើម្បីផ្ដល់ការលើកទឹកចិត្តដល់ SMEs ឲ្យចូលរួមក្នុងសេដ្ឋកិច្ចផ្លូវការ។ ក្នុងពេលជាមួយគ្នា គោលនយោបាយសារពើពន្ធ ក៏គួរជួយសម្របសម្រួលឲ្យ SMEs ទទួលបានអត្ថប្រយោជន៍ពី FDI តាមការលើកទឹកចិត្តឲ្យបង្កើតឧស្សាហកម្មបន្ទាប់បន្សំ សម្រាប់បម្រើឧស្សាហកម្មកម្មន្តសាលកម្ម ដូចជា ផលិតកម្មរថយន្តជាដើម។

## ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់ពាណិជ្ជកម្ម និងវិនិយោគ

រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា បានឈានទៅមុខច្រើនណាស់ហើយ ទាំងក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជា និងការធ្វើកំណែទម្រង់បទបញ្ញត្តិច្បាប់ ដើម្បីជួយសម្រួលដំណើរការពាណិជ្ជកម្ម។ ទោះយ៉ាងនេះក្ដី ស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅតែជាឧបសគ្គរាំងដល់គោលបំណងឈានឡើង នៅក្នុងខ្សែចង្វាក់បង្កើតតម្លៃខាងកសិកម្ម និងឧស្សាហកម្ម ព្រមទាំងធ្វើឲ្យផលិតករមានបន្ទុកចំណាយកាន់តែខ្ពស់។ នៅពេលសហគមន៍សេដ្ឋកិច្ចអាស៊ានជិតចូលមកដល់នេះ ការលុបបំបាត់ឧបសគ្គនានា នឹងកាត់បន្ថយបន្ទុកចំណាយផលិតកម្ម ជួយឲ្យផលិតករមានលក្ខណៈប្រកួតប្រជែង នៅក្នុងទីផ្សារក្នុងតំបន់ និងលើកទឹកចិត្តដល់ FDI ។

សមត្ថភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្តទន់ខ្សោយ ដែលនាំឲ្យមានការយឺតយ៉ាវ និងចំណាយខ្ពស់ក្នុងការដឹកជញ្ជូន វាកាត់បន្ថយវិនិយោគក្នុងគ្រប់វិស័យ ជាពិសេសនៅតាមតំបន់ដាច់ស្រយាលដែលគ្មានការតភ្ជាប់ និងក្រីក្រជាងគេ។ ការលើកកម្ពស់សមត្ថភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការតភ្ជាប់សំខាន់ខ្លាំងណាស់ក្នុងការ ជួយឲ្យរដ្ឋាភិបាលសម្រេចបានគោលដៅនាំចេញដ៏ធំធេងរបស់ខ្លួន, ជំរុញឲ្យមានមុខផលិតផលថ្មីៗ, និងពង្រឹងពង្រីកខ្សែចង្វាក់បង្កើតតម្លៃក្នុងវិស័យនានា។

ករណីអង្ករ ជាឧទាហរណ៍យ៉ាងច្បាស់មួយនៃ ឧបសគ្គរូបវន្តដែលរាំងគោលបំណងដ៏ធំធេងក្នុងការនាំចេញ។ រដ្ឋាភិបាលមានគោលដៅនាំចេញអង្ករ ១លានតោន/ឆ្នាំ នៅត្រឹមឆ្នាំ២០១៥ ដើម្បី

ក្លាយជាប្រទេសនាំចេញអង្ករធំបំផុតទី៣ នៅលើពិភពលោក។ ប៉ុន្តែបច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានរោងម៉ាស៊ីនកិនស្រូវគ្រប់គ្រាន់ទេ សម្រាប់កែច្នៃស្រូវឲ្យបានស្របតាមតម្រូវការទាំងផ្នែកបរិមាណ និងគុណភាព។ រោងម៉ាស៊ីនកិនស្រូវនានាដែលកំពុងដំណើរការសព្វថ្ងៃ មិនអាចប្រកួតប្រជែងនៅក្នុងតំបន់បានទេ ព្រោះមានចំណាយផលិតកម្មខ្ពស់ ដូចជាលើ អគ្គិសនី និងដឹកជញ្ជូន ជាដើម។ ទោះជារោងម៉ាស៊ីនកិនស្រូវអាចផលិតអង្ករបាន ១លានតោនក្នុងមួយឆ្នាំក្តី ក៏ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន (កំពង់ផែ, សមត្ថភាពដឹកជញ្ជូនផ្លូវគោក) មិនទាន់មានគ្រប់គ្រាន់សម្រាប់ដឹកជញ្ជូនអង្ករយ៉ាងច្រើនដូច្នេះដែរ។

បញ្ហាជាអាទិភាពមួយក្នុងការបង្កើនភាពប្រកួតប្រជែង ដែលអ្នកធ្វើគោលនយោបាយ និងអ្នកដឹកនាំសហគ្រាសអាជីវកម្មបានគូសបញ្ជាក់គឺ ការកែលំអការផ្គត់ផ្គង់អគ្គិសនី។ ឱនភាពផ្នែកថាមពល បានធ្វើឲ្យកម្ពុជាត្រូវពឹងផ្អែកលើ អគ្គិសនីនាំចូលពីប្រទេសជិតខាង ដែលមានថ្លៃខ្ពស់ និងមិនសូវបានទៀងទាត់ និងធ្វើឲ្យគុណភាពសេវាផ្គត់ផ្គង់ប្រែប្រួលខុសគ្នាក្នុងទូទាំងប្រទេស។ ជាក់ស្តែង ដោយសារការផ្គត់ផ្គង់អគ្គិសនីមិនសូវទៀងទាត់នេះ ម្ចាស់រោងម៉ាស៊ីនកិនស្រូវជារឿយៗត្រូវបង្ខំចិត្តប្រើម៉ាស៊ីនភ្លើងដើរដោយប្រេងឥន្ធនៈមានតម្លៃខ្ពស់ ហើយចំណាយផលិតកម្មក៏កើនឡើងជាខ្លាំង។

រដ្ឋាភិបាលបានប្តេជ្ញាចិត្តធ្វើការកែលំអយ៉ាងច្រើននូវហេដ្ឋារចនាសម្ព័ន្ធថាមពល ដើម្បីឲ្យកម្ពុជាក្លាយជាប្រទេសនាំចេញថាមពលមួយនៅត្រឹមឆ្នាំ២០២០ស្របតាមកម្មវិធីប្រករបៀងសេដ្ឋកិច្ចនៅមហាអនុតំបន់មេគង្គរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ក្នុងនេះត្រូវមានការកសាងទំនប់វារីអគ្គិសនីជាច្រើន បន្ទាប់ពីការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមបានចប់សព្វគ្រប់។ ក្នុងពេលជាមួយគ្នា រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវសម្រេចឲ្យបាននូវគោលដៅពង្រីកបណ្តាញបញ្ជូនថាមពលអគ្គិសនីក្នុងទូទាំងប្រទេស។ សហប្រតិបត្តិការរវាងរដ្ឋាភិបាល អ្នកធ្វើគោលនយោបាយ នឹងដៃគូក្នុងវិស័យឯកជន ជាធាតុផ្សំដ៏សំខាន់បំផុតក្នុងការសម្រេចគោលដៅទាំងនេះ។

ទន្ទឹមគ្នានឹងការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការកសាងសមត្ថភាពផ្នែកភស្តុភារ ដើម្បីអាចនាំចេញផលិតផលប្រកបដោយប្រសិទ្ធភាពខ្ពស់ ក៏សំខាន់ណាស់ដែរ ដើម្បីកាត់បន្ថយចំណាយផលិតកម្ម និងមានការតភ្ជាប់កាន់តែប្រសើររវាងផលិតករនៅកម្ពុជានឹងទីផ្សារក្នុងតំបន់ ជាពិសេស ផលិតករនៅតាមទីជនបទ។ រដ្ឋាភិបាលត្រូវជំរុញប្រព័ន្ធផ្គត់ផ្គង់ភស្តុភារច្រើនបែបយ៉ាង តាមផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក ដែលមានលក្ខណៈតភ្ជាប់ល្អទៅនឹងតំបន់ជនបទ និងបណ្តាញផ្គត់ផ្គង់ភស្តុភារក្នុងតំបន់។

## គន្លឹះក្នុងការកសាងសមត្ថភាព និងសហប្រតិបត្តិការ

គន្លឹះដែលធានាឲ្យកម្ពុជាមានកំណើន និងវិបុលភាពក្នុងប៉ុន្មានឆ្នាំខាងមុខគឺ ការកសាងសមត្ថភាពស្ថាប័នដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយ និងរបបនីតិរដ្ឋនៅក្នុងសង្គម។ មានក្របខ័ណ្ឌគោលនយោបាយបួនដែលកំណត់នូវកំណែទម្រង់ដ៏ចាំបាច់ៗ ដើម្បីសម្រេចចក្ខុវិស័យរបស់កម្ពុជាលើការអភិវឌ្ឍទៅថ្ងៃអនាគត គឺ ១) យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (RSIII), ២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP), ៣) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP) និង ៤) ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ (CV2030)។ សមត្ថភាពស្ថាប័នគឺត្រូវតែអភិវឌ្ឍឡើង ដើម្បីឲ្យកំណែទម្រង់ទាំងនេះអនុវត្តបានល្អ។

បញ្ហាចោទចម្បងមួយគឺ "ប្រាក់កម្រៃក្រៅផ្លូវការ" ប្រមូលយកដោយមន្ត្រីរដ្ឋាភិបាល ដែលនាំឲ្យមានបន្ទុកចំណាយខ្ពស់ក្នុងប្រតិបត្តិការជំនួញ, ភាពមិនប្រាកដប្រជានៅគ្រប់កម្រិតនៃទីផ្សារ, ការរាំងស្ទះដល់ពាណិជ្ជកម្ម, និង ការបង្វែរធនធានចេញពីវិនិយោគ។ ការសិក្សាមួយរបស់ CDRI រកឃើញថា ប្រាក់កម្រៃក្រៅផ្លូវការលើការនាំចេញអង្ករ បានធ្វើឲ្យបន្ទុកចំណាយកើនឡើង ១០ដុល្លារ/តោន ដែលបានបង្កឧបសគ្គដល់ភាពប្រកួតប្រជែងនៃអង្ករកម្ពុជា និងកាត់បន្ថយទុនដែលផលិតករអាចរកបានសម្រាប់វិនិយោគទៅក្នុងផលិតកម្មស្រូវអង្ករ។ ហេតុនេះ រដ្ឋាភិបាលត្រូវពង្រឹងផ្នែករដ្ឋបាលការិយាធិបតេយ្យ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ដើម្បីធានាឲ្យផលិតកម្ម និងការនាំចេញអង្ករកើនឡើងបាន ក្នុងប្រាំឆ្នាំខាងមុខនេះ។

ការកំណត់ ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព ត្រូវមានសហប្រតិបត្តិការ និងការសម្របសម្រួលរវាងមន្ទីរក្រសួង អ្នកធ្វើគោលនយោបាយ និងអ្នកពាក់ព័ន្ធនានា និងត្រូវមានការចូលរួមពីវិស័យឯកជន ដើម្បីញ៉ាំងឲ្យយន្តការសម្រាប់ជួយសម្រួលពាណិជ្ជកម្ម និងវិនិយោគ វាសមស្របតាមតម្រូវការជាក់ស្តែង។ អ្នកត្រូវចូលរួម មានជាអាទិ៍ អ្នកដឹកនាំក្រុមហ៊ុនធំៗ, តំណាង SMEs, ផលិតករស្រូវអង្ករ និង ស្ថាប័នស្រាវជ្រាវ។ យន្តការនានាត្រូវតែពង្រឹងឡើង ដើម្បីលើកកម្ពស់សហប្រតិបត្តិការអន្តរក្រសួង និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានរបស់វិស័យឯកជន តាមការកសាងភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ដើម្បីកសាង ប្រព័ន្ធការិយាធិបតេយ្យឲ្យមានប្រសិទ្ធភាពខ្ពស់ គេត្រូវតែធ្វើការងារនៅក្នុងក្របខ័ណ្ឌដែលមានស្រាប់។ ក្នុងនេះត្រូវមានជាអាទិ ការកសាងសមត្ថភាពអាជ្ញាធរមូលដ្ឋាន តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការពង្រឹងលទ្ធភាពប្រព័ន្ធតុលាការ តាមរយៈគម្រោងបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការ, និងការរៀបចំឡើងវិញនូវ កាំថ្នាក់ប្រាក់បៀវត្សរ៍របស់រដ្ឋបាលស៊ីវិលទាំងមូល។ ក្នុងការកសាងប្រព័ន្ធការិយាធិបតេយ្យនេះ ក៏ត្រូវមានការអភិវឌ្ឍស្ថាប័នថ្មីៗឲ្យបានស្របតាមតម្រូវការជាក់ស្តែង ដោយត្រូវឈរលើគោលការណ៍មានតម្លាភាព និងអភិបាលកិច្ចល្អ ដូចជាគណៈកម្មាធិការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាដើម ដើម្បីបំបាត់ភាពមិនប្រាកដប្រជាជួយសម្រួលដល់វិនិយោគិន។

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារអេអិនហ្សិតរ៉ូយ៉ាល់ ទេ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤

e-mail: cdri@cdri.org.kh, website: www.cdri.org.kh